THE SCHOOL DISTRICT OF PHILADELPHIA

ស្នងការដ្ឋាន
440 North Broad Street
Philadelphia, PA 19130

William R. Hite, Jr., Ed.D.
ស្នងការ

21 មករា 2021

ជូនចំពោះក្រុមគ្រួសាររបស់មណ្ឌលសិក្សាធិការនៃក្រុង Philadelphia ជាទីរាប់អាន៖

ឥឡូវនេះ ការចុះឈ្មោះចូលសាលាមត្តេយ្យសម្រាប់ឆ្នាំសិក្សា 2021-2022 បានបើកហើយ។ ប្រសិនបើអ្នកមានកូនប្រុស ឬកូនស្រីដែលនឹងមានអាយុប្រាំឆ្នាំនៅថ្ងៃ ឬមុនថ្ងៃទី1 ខែកញ្ញា សូមចុះឈ្មោះពួកគេត្រឹមថ្ងៃទី28 ខែឧសភា ដើម្បីផ្តល់ឱកាសឲ្យពួកគេ *អភិវឌ្ឍនៅអាយុ5ឆ្នាំ*។

មានមធ្យោបាយបួនយ៉ាងនៅក្នុងការចុះឈ្មោះ៖

- តាមអនឡាញ ដោយចូលទៅកាន់ គេហទំព័រសម្រាប់ការចុះឈ្មោះតាមអនឡាញ។
- ដោយផ្ទាល់នៅមជ្ឈមណ្ឌលអប់រំ តាមរយៈការណាត់តែប៉ុណ្ណោះ។ សូមទូរសព្ទទៅលេខ 215-400-4290 ដើម្បីធ្វើការណាត់ជួប។
- តាមទូរសព្ទ ដោយទូរសព្ទទៅសាលាក្នុងភូមិដ្ឋានរបស់អ្នក។ ស្វែងរកលេខទូរសព្ទសាលារបស់អ្នក នៅទីនេះ។
- តាមរយៈប្រអប់សំបុត្រនៅក្នុងកន្លែងអង្គុយរង់ចាំនៃមជ្ឈមណ្ឌលអប់រំ។ ស្វែងរកការណែនាំបន្ថែម នៅទីនេះ។

ការចុះឈ្មោះឲ្យបានត្រឹមថ្ងៃទី28 ខែឧសភា គឺជាការសំខាន់ ព្រោះវាផ្តល់ពេលវេលាដល់ក្រុមគ្រួសារ និងកុមារឲ្យបានជួបបុគ្គលិកសាលារៀន និងស្គាល់សាលាឲ្យបានជិតស្និទ្ធ ដែលជួយធ្វើឲ្យការចូលមត្តេយ្យសិក្សាប្រព្រឹត្តិទៅដោយរលូន។ មណ្ឌលសិក្សាធិការនឹងប្រារព្ធថ្ងៃបើកទទួលឲ្យចូលទស្សនកិច្ចសាលាមត្តេយ្យ នៅថ្ងៃទី2 ខែមីនា ហើយសប្តាហ៍ដែលបើកទទួលឲ្យចូលទស្សនកិច្ចសាលាមត្តេយ្យនឹងចាប់ផ្តើមនៅថ្ងៃទី3 ខែឧសភា។ ការបើកទទួលឲ្យចូលទស្សនកិច្ចអាចនឹងត្រូវបានធ្វើឡើងដោយនិម្មិត ឬដោយផ្ទាល់ អាស្រ័យលើរបៀបវារៈសុខភាព និងសុវត្ថិភាព។ សូមបន្តចូលទៅកាន់ philasd.org/thriveatfive សម្រាប់ព័ត៌មានថ្មីៗ។

មណ្ឌលសិក្សាធិការក៏មានកម្មវិធីមុនមត្តេយ្យសិក្សាផងដែរ ដែលមានទីតាំងសម្រាប់ថ្នាក់មុនមត្តេយ្យសិក្សាប្រហែល 200កន្លែងនៅទូទាំងក្រុង ដើម្បីបម្រើជូនអ្នកសិក្សាវ័យក្មេងខ្ចីបំផុតរបស់យើង។ កម្មវិធី

នេះផ្តល់ជូនកម្មវិធីសិក្សាដែលមានគុណភាពខ្ពស់ ការគាំទ្រទៅលើតម្រូវការពិសេស និងឱកាសសម្រាប់ឪពុក/ម្តាយក្នុងការចូលរួម។ សូមចុចទីនេះដើម្បីស្វែងយល់បន្ថែមអំពីថ្នាក់មុនមត្តេយ្យសិក្សា។

វត្តមាននៅថ្នាក់មុនមត្តេយ្យសិក្សា និងមត្តេយ្យសិក្សាគឺដឹកនាំកុមារទៅលើវិថីទៅរកភាពជោគជ័យទាំងនៅក្នុងសាលា និងក្នុងជីវិតរស់នៅ។ អំឡុងឆ្នាំទាំងនេះ ពួកគេរៀនចុះសម្រុងនឹងអ្នកដទៃ រាប់អានមិត្តភ័ក្តិ កសាងទំនុកចិត្ត និងចាប់ផ្តើមរៀនអាននិងសរសេរ ដែលសុទ្ធតែជាជំនាញសំខាន់ៗដែលជួយឲ្យកុមារអភិវឌ្ឍ។

សូមកុំពន្យារពេល។ ចុះឈ្មោះកូនរបស់អ្នកឲ្យចូលមត្តេយ្យសិក្សានៅថ្ងៃនេះ!

ដោយសេចក្តីគោរពរាប់អានអំពីខ្ញុំ



William R. Hite Jr., Ed.D.
ស្នងការ
មណ្ឌលសិក្សាធិការនៃក្រុង Philadelphia